# ឱសថស្ថាន Supercare រដ្ឋវិចថូរៀ

Victorian Supercare Pharmacies – Khmer | ភាសាខ្មែរ

**OFFICIAL**

ឱសថស្ថាន Supercare រដ្ឋវិចថូរៀ ត្រូវបានគាំទ្រដោយរដ្ឋាភិបាលរដ្ឋវិចថូរៀ ដើម្បីផ្តល់នូវលទ្ធភាពចូលប្រើប្រាស់ ការថែទាំសុខភាព និងដំបូន្មានប្រកបដោយវិជ្ជាជីវៈ។

ឱសថស្ថាន Supercare៖

- បើកធ្វើការ 24 ម៉ោងក្នុងមួយថ្ងៃ ប្រាំពីរថ្ងៃក្នុងមួយសប្តាហ៍ ដោយផ្តល់នូវលទ្ធភាពចូលប្រើប្រាស់ឱសថការីសម្រាប់ដំបូន្មាន ការផ្គត់ផ្គង់ថ្នាំពេទ្យ និងការចេញវេជ្ជបញ្ជា។
- រួមបញ្ចូលបន្ទប់ពិគ្រោះយោបល់ឯកជនមួយ ដែលមានសេវាកម្មគិលានុបដ្ឋាកឥតគិតថ្លៃនៅរវាងម៉ោង 6 ល្ងាច ដល់ម៉ោង 10 យប់ រៀងរាល់ថ្ងៃសម្រាប់ជំងឺ និងរបួសតិចតួច។
- ដំណើរការក្រោមឈ្មោះ និងម៉ាកយីហោឱសថស្ថានដែលបានសម្រាំងជ្រើសរើស ដើម្បីផ្តល់ជូនសេវាកម្មបន្ថែមនេះនៅក្នុង សហគមន៍របស់អ្នក។ ឱសថស្ថានទាំងនេះត្រូវបានគាំទ្រដោយរដ្ឋាភិបាលដើម្បីបើកដំណើរការក្រោយម៉ោងធ្វើការ ប្រាំពីរថ្ងៃក្នុងមួយសប្តាហ៍ ហើយមានបន្ទប់ពិគ្រោះយោបល់ឯកជនដោយឡែកពិសេសមួយសម្រាប់គិលានុបដ្ឋាក ដើម្បីធានានូវភាពឯកជនក្នុងអំឡុងពេលអញ្ជើញទៅពិនិត្យរបស់អ្នក។
- គោរពភាពឯកជនរបស់អ្នក។ ព័ត៌មានសុខភាពរបស់អ្នកនឹងត្រូវបានចែករំលែក ដោយមានការយល់ព្រមពីអ្នក និងសម្រាប់គោលបំណងជាក់លាក់បំផុត រួមទាំងជាមួយវេជ្ជបណ្ឌិតជម្មតារបស់អ្នកតែប៉ុណ្ណោះ។
- មានលទ្ធភាពចូលប្រើប្រាស់សេវាកម្មអ្នកបកប្រែផ្ទាល់មាត់។
- មានអ្នកយាមសន្តិសុខនៅនឹងកន្លែងនៅពេលយប់ ហើយប្រសិនបើស្ថានភាពតម្រូវ នឹងមានការចូលរួមពីសេវាកម្មសង្គ្រោះ បន្ទាន់ដែលសមស្រប។
- មានស្តុកឱសថថែទាំសម្រាលការឈឺចាប់តាមស្តង់ដារ។

# សេវាកម្មគិលានុបដ្ឋាក

- មានផ្តល់ជូនគិលានុបដ្ឋាកដែលបានចុះបញ្ជីស្របច្បាប់ សម្រាប់ការពិគ្រោះយោបល់ជារៀងរាល់យប់ រវាងម៉ោង 6 ល្ងាច ដល់ម៉ោង 10 យប់។
- គិលានុបដ្ឋាយកអាចវាយតម្លៃ និងព្យាបាលអ្នកណាម្នាក់ដែលមានបញ្ហាសុខភាពតិចតួចដូចជាកន្ទួលស្បែក គ្រុនក្តៅ និងសត្វល្អិតខាំ ព្រមទាំងព្យាបាលការរលាក ស្នាមកាត់ និងស្នាមជាំតិចតួច។ ពួកគេក៏នឹងអាចពិនិត្យសម្ពាធឈាម ចាក់ថ្នាំបង្ការរោគ និងផ្តល់ជូនដំបូន្មានអំពីរបៀបរស់នៅ និងព័ត៌មានសុខភាពផងដែរ។
- គិលានុបដ្ឋាកអាចមានផ្តល់ជូនដើម្បីចាត់ចែងការចាក់ថ្នាំបង្ការរោគមួយចំនួន ដូចជាការចាក់វ៉ាក់សាំងរោគក្អកមាន់ និង គ្រុនផ្តាសាយ។ ពួកគេក៏អាចចាត់ចែងការចាក់ថ្នាំបង្ការរោគតាមវេជ្ជបញ្ជារបស់វេជ្ជបណ្ឌិតផងដែរ។
- គិលានុបដ្ឋាកដែលបម្រើក្នុងឱសថស្ថាន Supercare មិនអាចចេញវេជ្ជបញ្ជាបានទេ។ ប្រសិនបើមានការតម្រូវឱ្យមាន ការវាយយតម្លៃឡើងវិញផ្នែកវេជ្ជសាស្ត្រ គិលានុបដ្ឋាកនឹងណែនាំទៅកាន់អ្នកផ្តល់សេវាកម្មសុខភាពសមស្របផ្សេងទៀត។
- អ្នកជំងឺត្រូវបានគេពិនិត្យតាមមូលដ្ឋានមកដល់មុន នឹងត្រូវបានពិនិត្យមុន។ មិនចាំបាច់ការណាត់ពេលជួបទេ។ ប្រសិនបើស្ថានភាពរបស់បុគ្គលនោះតម្រូវការថែទាំកម្រិតកាន់តែខ្ពស់ ពួកគេត្រូវបានបញ្ជូនទៅកាន់សេវាថែកម្ម ដែលសមស្របជាង។
- គ្មានការគិតថ្លៃលើការពិគ្រោះយោបល់ដើម្បីទៅជួបគិលានុបដ្ឋាកនៅឱសថស្ថាន Supercare ទេ។ ការផ្គត់ផ្គង់ផ្នែក វេជ្ជសាស្ត្រដែលគិលានុបដ្ឋាកប្រើប្រាស់ក្នុងអំឡុងពេលពិគ្រោះយោបល់ ក៏ឥតគិតថ្លៃផងដែរ។ អ្នកជំងឺអាចជ្រើសរើស ទិញផលិតផលបន្ថែមពីឱសថស្ថានក៏បានដែរ។
- អ្នកមិនចាំបាច់ត្រូវការប័ណ្ណ Medicare ទេ។ សេវាកម្មនេះមានសម្រាប់ពលរដ្ឋវិចថូរៀ និងអ្នកមកទស្សនារដ្ឋនេះគ្រប់រូប។
- ក្នុងករណីខ្លះ ទម្រង់ព្យាបាលដែលសមស្របបំផុត អាចមានពីវេជ្ជបណ្ឌិតព្យាលបាលរោគទូទៅ។ គិលានុបដ្ឋាក អាចណែនាំឱ្យអ្នកទៅជួប GP ទៀងទាត់របស់អ្នក ពេលណា GP នៅបម្រើការ។ គិលានុបដ្ឋាករបស់ឱសថស្ថាន Supercare អាចណែនាំអ្នកទៅកាន់សេវាកម្មក្រោយម៉ោងធ្វើការក្នុងតំបន់ ឬសេវាកម្មវេជ្ជសាស្ត្រផ្សេងទៀត។ ដោយមានការយល់ព្រមពីអ្នក គិលានុបដ្ឋាកនឹងផ្តល់សេចក្តីសង្ខេបជាលាយលក្ខណ៍អក្សរជូនវេជ្ជបណ្ឌិតរបស់អ្នក ជាមួយនឹងព័ត៌មានលម្អិតអំពីហេតុផលនានាដែលអ្នកបានអញ្ជើញទៅឱសថស្ថាន Supercare។

# ទីតាំងនានា

មានឱសថស្ថាន Supercare ចំនួនម្ភៃកន្លែង បើកនៅពេញទូទាំងរដ្ឋវិចថូរៀ
មានប្រាំមួយកន្លែងមានទីតាំងនៅក្នុងតំបន់នានា៖
ចំណាំ៖ ម៉ោងឱសថស្ថានអាចប្រែប្រួល។ សូមទាក់ទងឱសថស្ថាន ឬពិនិត្យ Google មុនពេលអញ្ជើញទៅ។

| **តំបន់** | **ទំនាក់ទំនង** | **ម៉ោងធ្វើការ** |
|---|---|---|
| Ballarat | UFS Dispensaries<br>717 Sturt Street,<br>Ballarat<br>ទូរសព្ទ៖ 5331 9811 | 7 ព្រឹក - 11 យប់ 7<br>ថ្ងៃក្នុងមួយសប្តាហ៍ |
| Bendigo | Bendigo UFS Pharmacies<br>Corner View and Barnard<br>Streets<br>Bendigo<br>ទូរសព្ទ៖ 5443 4610 | 7 ព្រឹក - 11 យប់ 7<br>ថ្ងៃក្នុងមួយសប្តាហ៍ |
| Craigieburn | Chemist Discount Centre<br>2A/340 Craigieburn Road,<br>Craigieburn | 7 ព្រឹក - 11 យប់ 7<br>ថ្ងៃក្នុងមួយសប្តាហ៍ |

| | | |
|---|---|---|
| | ទូរសព្ទ៖ 9308 4981 | |
| Hoppers Crossing | Chemist Warehouse<br>Shop 24-25, 428 Old Geelong Rd<br>Hoppers Crossing<br>ទូរសព្ទ៖ 9931 0040 | 7 ព្រឹក - 11 យប់ 7 ថ្ងៃក្នុងមួយសប្តាហ៍ |
| Melton | Chemist Warehouse<br>Unit 4 Melton Gateway, 66-84 High St,<br>Melton<br>ទូរសព្ទ៖ 9746 8733 | 7 ព្រឹក - 11 យប់ 7 ថ្ងៃក្នុងមួយសប្តាហ៍ |
| Mildura | Chemist Warehouse<br>114A -118 Langtree Ave,<br>Mildura<br>ទូរសព្ទ៖ 5023 2383 | 7 ព្រឹក - 11 យប់ 7 ថ្ងៃក្នុងមួយសប្តាហ៍ |
| Traralgon | Chemist Warehouse<br>92 Franklin St,<br>Traralgon<br>ទូរសព្ទ៖ 5174 2003 | 7 ព្រឹក - 11 យប់ 7 ថ្ងៃក្នុងមួយសប្តាហ៍ |
| Yarraville | Carnovale Pharmacy<br>149 Somerville Road,<br>Yarraville<br>ទូរសព្ទ៖ 9314 7557 | 7 ព្រឹក - 11 យប់ 7 ថ្ងៃក្នុងមួយសប្តាហ៍ |

ដើម្បីទទួលបានឯកសារនេះក្នុងទម្រង់មួយផ្សេងទៀត សូមទូរសព្ទលេខ 1300 650 172 ដោយប្រើសេវាកម្ម ជាតិផ្នែកប្រាស្រ័យទាក់ទងជាមួយជនពិការ លេខ 13 36 77 ប្រសិនបើត្រូវការ ឬផ្ញើអ៊ីមែលទៅអង្គភាពសុខភាព បឋម មាត់ និងសហគមន៍ ឱសថស្ថាន Supercare <Supercarepharmacies@health.vic.gov.au>។

បានផ្តល់សិទ្ធិអនុញ្ញាត និងបោះពុម្ពផ្សាយដោយរដ្ឋាភិបាលរដ្ឋវិចថូរៀ 1 Treasury Place, Melbourne។

©រដ្ឋវិចថូរៀ ប្រទេសអូស្ត្រាលី ក្រសួងសុខាភិបាល ខែកក្កដា ឆ្នាំ 2023។

អាចរកបាននៅតាម Better Health Channel < https://www.betterhealth.vic.gov.au/health/servicesandsupport/victorian-supercare-pharmacies >